ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
លេខ៖ បព ៣៧/២០២៥ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

## លទ្ធផលនៃការអញ្ជើញចូលរួមរបស់ ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅក្នុងកិច្ចពិភាក្សាទូទៅនៃមហាសន្និបាតអ.ស.ប. លើកទី៨០ នៅទីក្រុងញូវយ៉ក

តាមការចាត់តាំងរបស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី**, **ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា ចូលរួមកិច្ចពិភាក្សាទូទៅនៃមហាសន្និបាតអ.ស.ប.លើកទី៨០ ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៣-២៩ ខែកញ្ញា ឆ្នាំ២០២៥ នៅទីក្រុងញូវយ៉ក ក្រោមមូលបទ **«រួមគ្នាដើម្បីភាពប្រសើរឡើង៖ ៨០ឆ្នាំ និងច្រើនឆ្នាំទៀត ដើម្បីសន្តិភាព ការអភិវឌ្ឍ និងសិទ្ធិមនុស្ស»**។

ក្នុងឱកាសខួបលើកទី៨០ នៃការបង្កើតអ.ស.ប. កិច្ចពិភាក្សាទូទៅនៃមហាសន្និបាតអ.ស.ប. បានទទួលការអំពាវនាវយ៉ាងច្រើនលើសលុបពីបណ្តាប្រមុខរដ្ឋ/រដ្ឋាភិបាល ឱ្យពង្រឹងយន្តការពហុភាគីនិយម និងចូលរួមប្តេជ្ញាចិត្តរួមគ្នាឡើងវិញក្នុងការដោះស្រាយបញ្ហាប្រឈមជាសកល។ បណ្តាថ្នាក់ដឹកនាំបានសង្កត់ធ្ងន់លើតួនាទីដ៏សំខាន់របស់អ.ស.ប. សម្រាប់កិច្ចសហប្រតិបត្តិការរវាងរដ្ឋនិងរដ្ឋ និងបានគូសបញ្ជាក់ពីអាទិភាពសំខាន់ៗ រួមមាន ការរក្សាសន្តិភាព និងសន្តិសុខសកល, ការបញ្ចប់សង្គ្រាម និងអស្ថិរភាព, ការជំរុញការកែទម្រង់ប្រព័ន្ធអ.ស.ប., ការរៀបចំលិខិតបទដ្ឋានគ្រប់គ្រងបញ្ញាសិប្បនិមិត្ត, ការជំរុញការសម្រេចបានការអភិវឌ្ឍប្រកបដោយចីរភាព, ការធ្វើសកម្មភាពជាក់លាក់ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ និងការធានាថាការជ្រើសតាំងអគ្គលេខាធិការអ.ស.ប.ថ្មី សម្រាប់អាណត្តិបន្ទាប់ប្រកបដោយសមភាពយេនឌ័រ។ បណ្តាថ្នាក់ដឹកនាំកំពូលក៏បានគូសបញ្ជាក់ពីភាពចាំបាច់នៃការពង្រឹងសាមគ្គីភាព ក្នុងការឆ្លើយតបទៅនឹងវិបត្តិមនុស្សធម៌, ការលើកកម្ពស់សិទ្ធិមនុស្ស និងការដោះស្រាយចំណោទដ៏ស្មុគស្មាញនៃបច្ចេកវិទ្យាទំនើបថ្មីៗ។

កិច្ចពិភាក្សាទូទៅជារួមបានបង្ហាញការប្តេជ្ញាចិត្តថា នៅចំពោះមុខនៃការខ្វែងគំនិតគ្នាយ៉ាងណាក៏ដោយ ការរួបរួមគ្នា និងកិច្ចសន្ទនា នឹងនៅតែជាជម្រើសតែមួយគត់ក្នុងការបន្តកិច្ចការរួមគ្នាសម្រាប់ទៅខាងមុខទៀត និងបានប្រកាសសន្យាក្នុងការពង្រឹងភាពជាដៃគូ និងការគោរពគោលការណ៍គ្រឹះនៃធម្មនុញ្ញអ.ស.ប. ដើម្បីធានាថា អ.ស.ប. នឹងបន្តនៅជាវេទិកាសម្រាប់ដោះស្រាយបញ្ហាប្រឈមសកលប្រកបដោយប្រសិទ្ធភាព និងបរិយាប័ន្ន។

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល : mfaic@mfaic.gov.kh

ក្នុងឱកាសនៃកិច្ចពិភាក្សាទូទៅ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានចូលរួមគូសបញ្ជាក់ពីភាពចាំបាច់នៃយន្តការពហុភាគីនិយម, ដោយអំពាវនាវឱ្យផ្តល់ទំនុកចិត្តឡើងវិញលើអង្គការសហប្រជាជាតិ, វិធានការការទូតឱ្យកាន់តែខ្លាំងជាងមុន និងស្ថាប័នដែលមានប្រសិទ្ធភាពនានា ដើម្បីប្រឈមមុខនឹងបញ្ហាសកល។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានរំលឹកពីប្រវត្តិសាស្ត្រដ៏ឈឺចាប់នៃសង្គ្រាម និងអំពើប្រល័យពូជសាសន៍របស់កម្ពុជា ដោយគូសបញ្ជាក់ពីការសម្រេចបានសន្តិភាព តាមរយៈគោលនយោបាយឈ្នះឈ្នះរបស់ **សម្តេចតេជោ ហ៊ុន សែន** ដែលបានក្លាយជាសសរគ្រឹះដ៏សំខាន់សម្រាប់កំណើនសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ និងវឌ្ឍនភាពលើវិស័យសុខាភិបាល ការអប់រំ សមភាពយេនឌ័រ សិទ្ធិមនុស្ស សកម្មភាពអាកាសធាតុ និងការចូលរួមចំណែកក្នុងប្រតិបត្តិការរក្សាសន្តិភាព។

ខណៈពេលដែលកម្ពុជាបានប្រែក្លាយពីប្រទេសដែលទទួល ទៅជាអ្នកផ្តល់សន្តិភាព និងស្ថេរភាព **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសម្តែងនូវក្តីបារម្ភយ៉ាងជ្រាលជ្រៅចំពោះភាពតានតឹងដែលកំពុងបន្តនៅតាមព្រំដែនជាមួយប្រទេសថៃ ដោយបានប្រកាសប្រឆាំងនឹងការរំលោភអធិបតេយ្យ និងអំពាវនាវឱ្យគោរពយ៉ាងម៉ឺងម៉ាត់លើបទឈប់បាញ់ កិច្ចសន្ទនា និងដំណោះស្រាយដោយសន្តិវិធី ស្របតាមច្បាប់អន្តរជាតិ។ កម្ពុជាបានអំពាវនាវឱ្យមានការគាំទ្រពីអាស៊ាន អង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិឱ្យជួយបន្ធូរបន្ថយភាពតានតឹង និងស្តារឡើងវិញនូវជំនឿទុកចិត្តរវាងប្រទេសទាំងពីរ។

ឆ្លៀតក្នុងឱកាសនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានជម្រាបជូនមហាសន្និបាត អំពីការវាយប្រហារឥតញញើត នាពេលថ្មីចុងក្រោយនេះរបស់ថៃ មកលើកម្ពុជា ដែលបានកើតឡើងនៅរសៀលថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៥។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានច្រានចោលទាំងស្រុងនូវការចោទប្រកាន់ថា កងកម្លាំងកម្ពុជាបានបើកការបាញ់ប្រហារមុន ដោយសង្កត់ធ្ងន់ថា កងទ័ពរបស់កម្ពុជាមិនធ្វើដូចការចោទប្រកាន់ ឬបានសងសឹកឡើយ ដែលនេះបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់ ពីការប្តេជ្ញាចិត្តដ៏មុតមាំរបស់កម្ពុជាចំពោះសន្តិភាព។

ជាទីបញ្ចប់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានបញ្ជាក់សារជាថ្មីពីការគាំទ្ររបស់កម្ពុជាចំពោះការធ្វើកំណែទម្រង់របស់អង្គការសហប្រជាជាតិ ដើម្បីបង្កើនវិធានការការទូត ពង្រឹងតួនាទីរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ពង្រីកសមាជិកភាពនៃក្រុមប្រឹក្សាសន្តិសុខ និងជំរុញប្រតិបត្តិការថែរក្សាសន្តិភាព។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានអំពាវនាវឱ្យប្រទេសទាំងអស់គោរពចក្ខុវិស័យដំបូងរបស់អង្គការសហប្រជាជាតិ ដោយជ្រើសរើសកិច្ចសហប្រតិបត្តិការ កិច្ចសន្ទនា និងសេចក្តីសង្ឃឹម ជំនួសឱ្យជម្លោះ និងការបែងចែក។

នៅក្នុងឱកាសនៃកិច្ចពិភាក្សារបស់មហាសន្និបាតអង្គការសហប្រជាជាតិ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មានជំនួបទ្វេភាគីជាមួយឯកឧត្តម António Guterres អគ្គលេខាធិការអង្គការសហប្រជាជាតិ និងសមភាគីមួយចំនួនទៀត រួមមាន ប្រធានកាកបាទក្រហមអន្តរជាតិ រដ្ឋមន្ត្រីការបរទេសសាធារណរដ្ឋកូរ៉េ ជប៉ុន ហុងគ្រី សាំងលូស៊ី ន័រវែស រុស្ស៊ី និងហ្គាំប៊ី។ ជំនួបពិភាក្សានេះបានផ្តោតលើការពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី ក៏ដូចជាការបង្កើនកិច្ចសហប្រតិបត្តិការក្នុងពហុភាគី។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានយកឱកាសនោះរៀបរាប់ត្រួសៗ ជូនរដ្ឋមន្ត្រីការបរទេសទាំងនោះ នូវបច្ចុប្បន្នភាពជម្លោះព្រំដែនជាមួយប្រទេសថៃ និង

បានបញ្ជាក់សារជាថ្មីពីជំហររបស់កម្ពុជា ដើម្បីធ្វើយ៉ាងណាបន្ធូរបន្ថយភាពតានតឹង កសាងឡើងវិញនូវទំនុកចិត្ត និងការអនុវត្តកិច្ចព្រមព្រៀងកន្លងមកថ្មីៗនេះឱ្យបានពេញលេញ និងស្មោះត្រង់ ដើម្បីឈានទៅកាន់ទំនាក់ទំនងជាធម្មតាឡើងវិញរវាងប្រទេសទាំងពីរ។

បន្ថែមពីនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានជួបពិភាក្សាជាមួយរដ្ឋមន្ត្រីការបរទេសថៃ និងបានអញ្ជើញចូលរួមកិច្ចប្រជុំ ១+៣ (អនុរដ្ឋមន្ត្រីអាម៉េរិក និងរដ្ឋមន្ត្រីការបរទេសកម្ពុជា ម៉ាឡេស៊ី និងថៃ) ក្នុងគោលបំណងបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តរួម ដើម្បីដោះស្រាយជម្លោះព្រំដែនដោយសន្តិវិធី ដោយស្តារឡើងវិញនូវការជឿទុកចិត្តចំពោះការវិលទៅរកប្រក្រតីភាពវិញ សម្រាប់ផលប្រយោជន៍រួមរបស់ប្រជាជន និងប្រទេសទាំងពីរ។

ជាមួយគ្នានេះ គណៈប្រតិភូកម្ពុជាបានចូលរួមយ៉ាងសកម្មក្នុងកិច្ចប្រជុំកម្រិតខ្ពស់ និងព្រឹត្តិការណ៍អមនានា រួមមាន កិច្ចប្រជុំកម្រិតខ្ពស់ដើម្បីរំលឹកខួបលើកទី៨០ របស់អង្គការសហប្រជាជាតិ ជាមួយនឹងការបញ្ជាក់សារជាថ្មីឡើងវិញពីតួនាទីរបស់អង្គការសហប្រជាជាតិ ក្នុងការថែរក្សាសន្តិភាព សន្តិសុខ និងការអភិវឌ្ឍប្រកបដោយចីរភាព។ គណៈប្រតិភូកម្ពុជា ក៏បានចូលរួមកិច្ចប្រជុំកម្រិតខ្ពស់ដើម្បីរំលឹកខួបលើកទី៣០ ឆ្នាំ នៃសន្និសីទពិភពលោកលើកទី៤ ដើម្បីស្ត្រី ដែលបានរៀបចំដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ដោយរំលឹកឡើងវិញពីវឌ្ឍនភាព និងបញ្ហាប្រឈមក្នុងការជំរុញសមភាពយេនឌ័រ និងការអភិវឌ្ឍប្រកបដោយចីរភាព និងគូសបញ្ជាក់ពីវឌ្ឍនភាពសកលលើរបៀបវារៈ ឆ្នាំ២០៣០។

បន្ថែមលើនេះទៀត កម្ពុជាបានចូលរួមកិច្ចប្រជុំកម្រិតខ្ពស់នៃគំនិតផ្តួចផ្តើមអភិវឌ្ឍន៍សកល ក្រោមប្រធានបទ «**ប្តេជ្ញាឡើងវិញចំពោះគោលបំណងដើមរបស់យើង រួបរួមគ្នាដើម្បីកសាងអនាគតកាន់តែភ្លឺថ្លានៃការអភិវឌ្ឍសកល**» ដែលកិច្ចប្រជុំបានគូសបញ្ជាក់ពីកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការដោះស្រាយបញ្ហាប្រឈមរួម។ គណៈប្រតិភូក៏បានចូលរួមផងដែរនៅក្នុងកិច្ចប្រជុំកំពូលលើកទី១ ក្នុងពីរឆ្នាំម្តង សម្រាប់សេដ្ឋកិច្ចសកលដែលមាននិរន្តរភាព បរិយាប័ន្ន និងមានភាពធន់ ដែលផ្តោតលើការពង្រឹងស្ថេរភាពហិរញ្ញវត្ថុសកល និងចូលរួមក្នុងកិច្ចប្រជុំប្រចាំឆ្នាំលើកទី៤៩ របស់រដ្ឋមន្ត្រីការបរទេសនៃក្រុមប្រទេស ៧៧ និងចិន ដែលផ្តោតលើសាមគ្គីភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសកំពុងអភិវឌ្ឍន៍។

កម្ពុជាក៏បានចូលរួមក្នុងព្រឹត្តិការណ៍ពិសេសស្តីពីអាកាសធាតុ ដែលពិភាក្សាលើដំណោះស្រាយសកម្មភាពអាកាសធាតុបន្ទាន់ និងកិច្ចប្រជុំស្តីពីបញ្ញាសិប្បនិម្មិត និងសន្តិភាពនិងសន្តិសុខអន្តរជាតិ ដែលបានពិនិត្យលើកាលានុវត្តភាព និងហានិភ័យនានា នៃបច្ចេកវិទ្យាដែលកំពុងកើតមាន។ គណៈប្រតិភូក៏បានចូលរួមព្រឹត្តិការណ៍ស្តីពីការកែលម្អកិច្ចសហប្រតិបត្តិការ ដើម្បីទទួលបាននូវដែនសមុទ្រដែលមានសុវត្ថិភាព និងស្ថេរភាព ដោយបញ្ជាក់ពីសារៈសំខាន់នៃសន្តិសុខដែនសមុទ្រ ព្រមទាំងការចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន-សម្ព័ន្ធប៉ាស៊ីហ្វិក លើកទី៨ ដែលលើកកម្ពស់ការទូតសភាតំបន់ និងពិធីប្រកាសធម្មនុញ្ញសកលស្តីពីកំណែទម្រង់ការថែទាំកុមារ ដែលផ្តោតលើការធ្វើឱ្យប្រសើរឡើងនៃស្តង់ដារសកលសម្រាប់សុខុមាលភាពកុមារ។

ក្រៅពីនេះ កម្ពុជាក៏បានចូលរួមក្នុងកិច្ចប្រជុំក្រៅផ្លូវការថ្នាក់រដ្ឋមន្ត្រីនៃក្រុមប្រឹក្សាសន្និសីទស្តីពីទំនាក់ទំនងនិងវិធានការកសាងទំនុកចិត្តនៅអាស៊ី (CICA) ដែលបានជំរុញកិច្ចសន្ទនាសន្តិសុខតំបន់ និងកិច្ចប្រជុំ

លើកទី២ នៃរដ្ឋមន្ត្រីការបរទេស G20 ដែលបានពិភាក្សាអំពីអភិបាលសេដ្ឋកិច្ចសកល។ ប្រតិភូក៏បានចូលរួមក្នុងកិច្ចប្រជុំកម្រិតខ្ពស់លើកទី៤ ស្តីពីការបង្ការ និងការគ្រប់គ្រងជម្ងឺមិនឆ្លង និងការលើកកម្ពស់សុខភាពផ្លូវចិត្ត និងភាពសុខដុម ផ្តោតលើភាពធន់សុខភាព និងបានចូលរួមសន្និសីទកម្រិតខ្ពស់ក្នុងការរំលឹកខួបអនុស្សាវរីយ៍ ៣០ឆ្នាំ នៃកម្មវិធីសកម្មភាពពិភពលោកសម្រាប់យុវជន ដែលបញ្ជាក់ឡើងវិញនូវតួនាទីសំខាន់របស់យុវជនក្នុងការអភិវឌ្ឍប្រកបដោយចីរភាព។

ជាមួយគ្នានេះដែរ គណៈប្រតិភូបានចូលរួមក្នុងកិច្ចប្រជុំកម្រិតខ្ពស់ ដើម្បីរំលឹក និងលើកកម្ពស់ទិវាអន្តរជាតិសម្រាប់ការលុបបំបាត់ទាំងស្រុងនៃអាវុធនុយក្លេអ៊ែរ ដែលបានបញ្ជាក់ពីការប្តេជ្ញាចិត្តសកលចំពោះការរំសាយសព្វាវុធ និងកិច្ចប្រជុំរដ្ឋមន្ត្រីប្រចាំឆ្នាំនៃក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ដែលផ្តោតលើកិច្ចសហប្រតិបត្តិការអភិវឌ្ឍ និងការគាំទ្រប្រទេសអភិវឌ្ឍន៍តិចតួច។

តាមរយៈការចូលរួមយ៉ាងសកម្មនៅក្នុងសប្តាហ៍កម្រិតខ្ពស់នៃ UNGA80 កម្ពុជាបានបញ្ជាក់ជាថ្មីម្តងទៀតពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការពង្រឹងពហុភាគីនិយម ធ្វើឱ្យប្រសើរឡើងនូវសន្តិភាព និងការអភិវឌ្ឍ ព្រមទាំងការចូលរួមប្រកបដោយការស្ថាបនាក្នុងកិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។

ថ្ងៃចន្ទ ៨កើត ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៥